**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ១៦៤ / បក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៤

# ប្រកាស

## ស្តីពី

## គំរូវិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ មិថុនា ឆ្នាំ២០០៩ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១._**

ប្រកាសនេះមានគោលបំណងដាក់ចេញនូវគំរូវិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារ ដូចមានក្នុងអនុក្រឹត្យ លេខ ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។

**ប្រការ ២._**

គំរូវិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារ ត្រូវអនុលោមតាមគំរូនៃឧបសម្ព័ន្ធដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ ៣._**

គំរូវិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤._**

អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានក្រុមអ្នកច្បាប់ អធិការ គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

**ថោង ខុន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- សាលារាជធានីខេត្ត
- សមាគមសណ្ឋាគារ
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## ស្តីពីទម្រង់គំរូវិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារថ្មី

## ប្រកាសលេខ..........ប្រ.ក.ចុះថ្ងៃទី..........ខែ..........ឆ្នាំ២០១៥

១. ឧបសម្ព័ន្ធទី១៖ ស្តីពីគំរូវិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារថ្មី

*Kingdom of Cambodia*
*Nation Religion King*

# *Certificate*

*This is to certify that Angkor Holiday Hotel has fulfilled the standard of Four Star of the hotel classification of Cambodia*

*2015-2017*

*Phnom Penh,.................................*

*Date of issue: ........./......./...............*
*Date of expire: ......../........../...........*

Dr. Thong Khon
Minister

## ២. ឧបសម្ព័ន្ធទី២៖ ស្តីពីការពណ៌នាអំពីគំរូវិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារថ្មី

វិញ្ញាបនបត្រចំណាត់ថ្នាក់សណ្ឋាគារគំរូថ្មីត្រូវបានរចនា និង រៀបចំឡើងតាមទម្រង់ដូចខាងក្រោម៖

១- ទម្រង់ :

ទម្រង់វិញ្ញាបនបត្រមានរាងបួនជ្រុងទ្រវែងបញ្ឈរ

៣- ទំហំ :

មានបណ្តោយ២៩.៧០ សម X ទទឹង ២១.០០ សម

៤- របៀបរចនាផ្ទៃ :

- ផ្ទៃវិញ្ញាបនបត្រត្រូវចែកជាពីរផ្នែកមានខាន់ដោយទម្រង់ខ្សែជារាងពត់ពែនដោយ៖
- ផ្ទៃផ្នែកពណ៌ទឹកប៊ិចចាស់មានផ្ទៃ១ភាគ៤នៃផ្ទៃសរុបដោយមានបង្កប់ក្បាច់សសរពេជ្រភ្ញីទេសអង្គរស្រាលនៅផ្នែកខាងក្រោយ
- ផ្ទៃផ្នែកពណ៌ប្រផេះស្រាលមានផ្ទៃ៣ភាគ៤នៃផ្ទៃសរុបគឺជាផ្ទៃលាត។

៤- និមិត្តសញ្ញានិងអក្សរ :

ក - នៅលើផ្ទៃពណ៌ទឹកប៊ិចចាស់មានរំលេចរូបនិងអក្សរដូចជា៖ និមិត្តសញ្ញាក្រសួងទេសចរណ៍ អក្សរជាភាសាអង់គ្លេស "Ministry of Tourism" លេខសម្គាល់ "No............" សសេរជាពណ៌លឿង និង រូបQR CODEដែលមានគែមពណ៌លឿងជុំវិញ។

ខ - នៅលើផ្ទៃពណ៌ប្រផេះស្រាលមានរំលេចអក្សរតាមខ្លឹមសារជាលំដាប់លំដោយពីលើទៅក្រោមដូចតទៅ៖

-អក្សរ "Kingdom of Cambodia" និង "Nation Religion King": ពណ៌ខ្មៅ

-រូបភាពក្បាច់ : ពណ៌ទឹកមាស

-អក្សរ "Certificate": ពណ៌ទឹកមាស

-ខ្លឹមសារពិពណ៌នាអំពីឈ្មោះ សណ្ឋាគារ និង ចំណាត់ថ្នាក់សណ្ឋាគារ ដោយមានប្រើពណ៌ខ្មៅនិង ពណ៌ទឹកមាស

-លេខសុពលភាព "2015-2017": ពណ៌ខ្មៅ

-ទីកន្លែង និងកាលបរិច្ឆេទ "Phnom Penh,................." : ពណ៌ខ្មៅ

-កាលបរិច្ឆេទចេញនិងផុតកំណត់ : ពណ៌ខ្មៅ